**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# សាររំលែកទុក្ខ

## សូមគោរពជូន

## លោកជំទាវ ម៉ៅ សាមឿន ឈា ថាំង និងក្រុមគ្រួសារ ចំពោះមរណភាព ឯកឧត្តមវេជ្ជបណ្ឌិត ឈា ថាំង អតីតរដ្ឋមន្ត្រីក្រសួងសុខាភិបាល

ខ្ញុំនិងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មានសេចក្តីសោកស្តាយជាពន់ពេក ក្រោយពីបានទទួលដំណឹងថា ឯកឧត្តមវេជ្ជបណ្ឌិត **ឈា ថាំង** អតីតរដ្ឋមន្ត្រីក្រសួងសុខាភិបាល បានទទួលមរណភាព កាលពីថ្ងៃចន្ទ ១៤ រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ៣:២៥ នាទីរសៀល ក្នុងជន្មាយុ ៨៧ ឆ្នាំ ដោយជរាពាធ។

ក្នុងវេលាពោរពេញដោយក្តីរំជួលចិត្តនិងសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំនិងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមចូលរួមសម្តែងនូវសេចក្តីសោកស្តាយ ស្រណោះ អាឡោះអាល័យជាទីបំផុត ចំពោះមរណភាពរបស់ឯកឧត្តមវេជ្ជបណ្ឌិត **ឈា ថាំង** ដែលជាការបាត់បង់ស្វាមី ឪពុក ឪពុកក្មេក ជីតា និងជីតាទួតជាទីស្រឡាញ់ដ៏ឧត្តុង្គឧត្តម ប្រកបដោយព្រហ្មវិហារធម៌ ហើយដែលជាកុលបុត្រដ៏ឆ្នើម ជាឥស្សរជន និងជាថ្នាក់ដឹកនាំជាន់ខ្ពស់មួយរូប ធ្លាប់បានធ្វើពលិកម្មក្នុងបុព្វហេតុ ជាតិ សាសនា និងព្រះមហាក្សត្រ តាមរយៈការចូលរួមចំណែកលើកកម្ពស់និងអភិវឌ្ឍវិស័យសុខាភិបាលកម្ពុជា ចាប់ពីក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩។

យើងខ្ញុំទាំងអស់គ្នា សូមឧទ្ទិសបួងសួងជូនវិញ្ញាណក្ខន្ធ ឯកឧត្តមវេជ្ជបណ្ឌិត **ឈា ថាំង** សូមអញ្ជើញទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកជំទាវ ព្រមទាំងក្រុមគ្រួសារ** មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីយើងខ្ញុំ៕

ថ្ងៃ ពុធ ១ កើត ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ២០២២

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ព្រុំ-សុខា**